(37)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សុខាភិបាល

៦I.សបស.មក

រាជធានីភ្នំពេញ, ថ្ងៃទី 03 ខែ 01 ឆ្នាំ២០០៦

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ជំរាបជូន**

**លោក.លោកស្រីប្រធានសេវាវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ**

**និង ជំនួយវេជ្ជសាស្ត្រឯកជនទាំងអស់:**

**កម្មវត្ថុ:** ការទុកដាក់កាកសំណល់វេជ្ជសាស្ត្រដោយឡែកពីសំរាមទូទៅ. ការវេចខ្ចប់ និងការប្រមូលយកទៅដុតកំទេចដោយឡ រឺ ការប្រើស្វូលុយស្យុងសំលាប់មេរោគ។

តបតាមកម្មវត្ថុខាងលើនេះ . ដោយក្រសួងសង្កេតឃើញថា មានកាកសំណល់វេជ្ជសាស្ត្រជាច្រើនទៅតាមគំនរសំរាមកន្លែងចាក់សំរាមនៅលាយឡំគ្នាជាមួយសំរាមផ្ទះបាយ ពិសេសម្ជុល-សឺរាំង សំឡីខ្ទុះ.ឈាមដែលជាគ្រោះថ្នាក់យ៉ាងខ្លាំងដល់ប្រជាជនទូទៅ. កាកសំណល់នេះវាផ្ទុកដោយមេរោគអាចចំលងដល់មនុស្ស-សត្វគ្រប់ពេលវេលា ហេតុដូច្នេះហើយដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង និងគ្រោះថ្នាក់ផ្សេងៗទៀត ក្រសួងសុខាភិបាល សូមធ្វើការណែនាំ ដល់ប្រធានសេវាវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រឯកជន ទាំងអស់ដូចតទៅ:

- បែងចែកកាកសំណល់វេជ្ជសាស្ត្រជាបីផ្នែក
  - ក-សំភារៈមុតហើយស្រួច ដូចជាសឺរាំង-ម្ជុល.កាំបិតវះកាត់
  - ខ-សំឡី.កំទេចកំទីសរីរាង្គ. សាក់សៀម
  - គ-សំបកដបថ្នាំ.ដបកែវសាំង ត្រូវដាក់ផ្សេងៗពីគ្នាហើយត្រូវទុកដាក់ ដោយឡែកពីកាកសំណល់ផ្ទះបាយ និងត្រូវដឹកជញ្ជូនដោយឡែកទៅដុតចោលនៅឡដែលមានលក្ខណៈសមស្រប។
- ត្រូវសហការជាមួយមជ្ឈមណ្ឌលជាតិ-មន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យបង្អែកខេត្ត-ក្រុង ស្រុកប្រតិបត្តិ ដែលមានឡដុតកំទេច។

អាស្រ័យហេតុនេះ សូមលោក.លោកស្រីប្រធានសេវាទាំងអស់ ជួយសហការអនុវត្តការងារនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ដើម្បីពង្រឹងគុណភាពគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ ដែលជាមធ្យោបាយមួយដ៏សំខាន់ដើម្បីទប់ស្កាត់នូវជំងឺឆ្លងនានា និងគ្រោះថ្នាក់ផ្សេងៗដែលអាចកើតមានឡើងដោយចៃដន្យ។

សូមលោក.លោកស្រីទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រដ្ឋ. ហុង_ស៊ុនហួត

**ចំលងជូន:**

- ក្រសួងបរិស្ថាន
- សាលារាជធានីភ្នំពេញ
- មន្ទីរសុខាភិបាលខេត្ត-ក្រុង
- ក្រុមហ៊ុនដឹកសំរាមខេត្ត-ក្រុង (ដើម្បីជាពត៌មាន)
- ឯកសារ. កាលប្បវត្តិ
- សាម៉ីខ្លួន